**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

លេខ៖១៨/២៣

# សេចក្ដីជូនដំណឹង
# ស្ដីពី
# កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក របស់ក្រុមហ៊ុន
# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក (ស្ថិតក្នុងដំណើរការផ្លាស់ប្ដូរជាផ្លូវការ)

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក (ស្ថិតក្នុងដំណើរការផ្លាស់ប្ដូរជាផ្លូវការ)**មាន កិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតទាំងអស់មេត្តាជ្រាបថា៖ កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក នឹងប្រព្រឹត្តិទៅនៅ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២៣ ដោយអនុលោមតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន កាលពីថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០២៣ ។ ការប្រជុំនេះនឹងត្រូវធ្វើឡើងដោយមានការខលហៅជាវីដេអូ។ ដូច្នេះការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះមានការកំណត់ដូចខាងក្រោម:

១. កាលបរិច្ឆេទកំណត់ទុក (Recorded date)៖ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២៣

២. កាលបរិច្ឆេទកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក៖ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២២ វេលាម៉ោង ២:០០ ដល់ម៉ោង ៤:៣០ រសៀល

៣. ទីកន្លែង: តាមរយៈការហៅជាវីដេអូ

៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ៖

- បទបង្ហាញនៃសេចក្ដីសម្រេចទី១៖ អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២
- បទបង្ហាញនៃសេចក្ដីសម្រេចទី២៖ ការបោះឆ្នោត និងតែងតាំងក្រុមប្រឹក្សាភិបាលសម្រាប់អណត្តិថ្មី
- បទបង្ហាញនៃសេចក្ដីសម្រេចទី៣៖ អនុម័តកំណត់ហេតុនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក វិសាមញ្ញ ២០២២
- បទបង្ហាញនៃសេចក្ដីសម្រេចទី៤៖ អនុម័តការតែងតាំងសវនករខាងក្រៅ (ដើម្បីបន្តសវនកម្មបន្ទាប់)
- បទបង្ហាញនៃសេចក្ដីសម្រេចទី៥: អនុម័តការបន្តសិទ្ធិសម្រាប់ការទិញភាគហ៊ុនត្រឡប់មកវិញ

` ម្ចាស់ភាគហ៊ុនដែលមិនអាចចូលរួមក្នុងការប្រជុំអនឡាញបាន អាចមានអ្នកតំណាងណាម្នាក់ដើម្បីចូលរួម និងបោះឆ្នោតលើសេចក្ដីសម្រេច (ប្រសិនបើមាន) ក៏ដូចជាយើងនឹងចែករំលែកប្រព័ន្ធនៃការហៅជាវីដេអូទៅកាន់អ្នកចុះឈ្មោះចូលរួម។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលបានរៀបចំនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣ នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិក lim.an@acledabank.com.kh huot.sophy@acledabank.com.kh និង op.rtp@acledabank.com.kh ពីធនាគារ អេស៊ីលីដា ភីអិលស៊ី ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ ជារៀងរាល់ ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២៣។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាអញ្ជើញឆ្លើយតបតាមរយៈសារអេឡិចត្រូនិដើម្បីកញ្ជាក់ពីការចូលរួមជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណវិនិយោគិន និងឈ្មោះ ចាប់ពី ថ្ងៃ១៤ ខែ មេសា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម:

- អាសយដ្ឋាន ៖ ផ្ទះលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- អ្នកទំនាក់ទំនង៖
  - លោក លីម អាន ប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
    អ៊ីម៉ែល: lim.an@acledabank.com.kh
  - លោក ហួត សុភី អនុប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
    អ៊ីម៉ែល: huot.sophy@acledabank.com.kh
  - លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ បុគ្គលិកផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
    អ៊ីម៉ែល: op.rtp@acledabank.com.kh

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក**

**(ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ)**